ប្រវត្តវិទ្យា

# សម័យសាធារណរដ្ឋខ្មែរ

## (1970-1975)

នៅដើមឆ្នាំ 1970 សម្តេច នរោត្តមសីហានុ មិនបានស្ថិតនៅក្នុងប្រទេសកម្ពុជាដោយព្រះអង្គចេញទៅព្យាបាលជំងឺនៅប្រទេសបារាំង រួចយាងទៅសហភាព សូវៀត។ ក្នុងឱកាសនោះ ឧត្តមសេនីយ៍ លន់ នល់ និង ព្រះអង្គស៊ីសុវត្ថិសិរីមតៈ និងបក្សពួកបានធ្វើសេចក្តីប្រកាសស្តីពីការផ្តួលរំលំព្រះអង្គពីអំនាចនៅថ្ងៃទី 18 មិនា 1970។ ស្ថានភាពទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជាស្ថិតក្នុងភាពវិកវរយ៉ាងខ្លាំង។

### ➷ សកម្មភាពសម្តេចនរោត្តមសីហានុក្រោយរដ្ឋប្រហារ 18 មិនា 1970

- នៅថ្ងៃទី 23 មិនា 1970 សម្តេនរោត្តមសីហានុបានថ្លែងការនៅទីក្រុង ប៉េកាំង ដោយប្រកាសមិនទទួលស្គាល់រដ្ឋាភិបាល និង រដ្ឋសភាសាធារណរដ្ឋខ្មែរ។
- ព្រះអង្គបានប្រកាសពីបំណាងចង់បង្កើតរណសិរ្សរួបរួមជាតិ និង កងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា។

### ➷ គោលដៅរបស់រដ្ឋាភិបាលរួបរួមជាតិ

គោលដៅរបស់រដ្ឋាភិបាលរួបរួមជាតិ មានន័យថាបង្រួបបង្រួមឯកភាពជាតិសំរាប់ការតស៊ូប្រឆាំងអំពើឈ្លានពាននៃពួកចក្រពត្តិអាមេរិចដើម្បីផ្តួលរំលំរបបសាធារណរដ្ឋខ្មែរហើយកសាងប្រទេសកម្ពុជាឲ្យសំបូររុងរឿងស្របតាមឆន្ទះរបស់ប្រជាជនកម្ពុជា។ គោលដៅនេះបានសម្រេចនៅឆ្នាំ 1975 គឺ រណសិរ្ស រួបរួមជាតិកម្ពុជាបានរំដោះ 90% នៃទឹកដីកម្ពុជាទាំងមូល។

### ➷ មូលហេតុដែលនាំអោយរបបសាធារណរដ្ឋបរាជ័យ

- ប្រជាជនក្នុងតំបន់រំដោះ ក៍ដូច នៅក្រុងភ្នំពេញនឿយណាយ និង របបសាធារណរដ្ឋខ្មែរដែលប្រកបដោយអំពើរពុករលួយ។
- ពួកខ្មែរក្រហមបានដាក់មីន នៅគ្រប់ច្រកចេញចូលតាមផ្លូវទឹកមកកាន់ភ្នំពេញដើម្បីផ្តាច់ការដឹកជញ្ជូន អង្ករ និង គ្រាប់រំសេរ។
- ជំនួយពីអាមេរិចត្រូវកាត់ផ្តាច់ទាំងស្រុងដោយពួកខ្មែរក្រហម និង ឡោមព័ទ្ធទីក្រុងភ្នំពេញ។
- ប្រជាពលរដ្ឋពេញចិត្តនឹងការដឹកនាំរបស់ពួកកុំមួយនីស្ត។

### ➷ ផលលំបាកនៃសង្គ្រាមពីឆ្នាំ 1970-1975

- ប្រជាជនជាង 1លាននាក់បានត្រូវបាត់បង់ជីវិត ហើយ បន្សល់ទុកនៅអ្នករបួស ក្មេងកំព្រា ជនពិការជាច្រើននាក់។
- ប្រជាពលរដ្ឋភៀសខ្លួនរាប់សែននាក់ គ្មានទីលំនៅ និង ព្រាត់ប្រាស់គ្រួសារ។
- នៅក្នុងប្រទេស រោងចក្រ $\frac{4}{5}$ ត្រូវបានបំផ្លាញ ចម្ការកៅស៊ូ $\frac{2}{3}$ ត្រូវបាត់បង់ផ្លូវថ្នល់ផ្លូវដែក 70%-80% ត្រូវខូចខាត កំពុងផែពាណិជ្ជកម្មទាំងទឹកសាប និង ទឹកប្រៃត្រូវខូចខាតជាទម្ងន់។
- ផលិតផលខាងកសិកម្ម និង ឧស្សាហាកម្មត្រូវបានអសកម្មភាពស្ទើរទាំងស្រុង។
- ទំនិញឡើងថ្លៃ ប្រាក់រៀលចុះថោក ភាពឥតការងារធ្វើអំពើរពុករលួយមានកំរិតខ្ពស់។
- ប្រទេសជាតិទាំងមូលជួបបញ្ហាច្របូកច្របល់ខ្វះសណ្តាប់ធ្នាប់ អស្ថិរភាពនយោបាយកើតមានភាពអនាធិបតេយ្យ កូនទាហានបាត់បង់វិន័យ នាយទាហានចេញពីជួរកងទ័ព ហើយចុះចូលមករួមរស់ជាមួយកម្លាំងនៃអ្នកស្នេហាជាតិ។

រៀបរៀងដោយ អ៊ុក ភារិទ្ធ